## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្តូរឈ្មោះស្រុកព្រៃវែង ទៅជាស្រុកស្វាយអន្ទរ និងការបង្កើតក្រុងព្រៃវែង នៃខេត្តព្រៃវែង

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### សម្រេច

**មាត្រា ១.-**

ត្រូវបានប្តូរឈ្មោះស្រុកព្រៃវែង ទៅជា ស្រុកស្វាយអន្ទរ នៃខេត្តព្រៃវែង។

www.pheakdeylaw.com

មាត្រា ២.-

ត្រូវបានបង្កើត ក្រុងព្រៃវែង នៃខេត្តព្រៃវែង ដោយកាត់យកឃុំចំនួនបី គឺ ឃុំកំពង់លាវ ឃុំជើងទឹក និង ឃុំបារាយណ៍ ពីស្រុកកំពង់លាវ នៃខេត្តព្រៃវែង ។

ព្រំប្រទល់រដ្ឋបាលនៃ ក្រុងព្រៃវែង ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ៣.-

ត្រូវបានប្តូរឃុំ ចំនួនបីនៃ ក្រុងព្រៃវែង ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំកំពង់លាវ | ទៅជា | សង្កាត់កំពង់លាវ |
| ២- ឃុំបារាយណ៍ | ទៅជា | សង្កាត់បារាយណ៍ |
| ៣- ឃុំជើងទឹក | ទៅជា | សង្កាត់ជើងទឹក |

មាត្រា ៤.-

ត្រូវផ្ទេរទីតាំងសាលាស្រុកកំពង់លាវដែលស្ថិតនៅក្នុងសង្កាត់កំពង់លាវ ទៅជាសាលា ក្រុងព្រៃវែង ។

មាត្រា ៥.-

ទីតាំងសាលាស្រុកកំពង់លាវ ត្រូវស្ថិតនៅក្នុងឃុំតាកោ ស្រុកកំពង់លាវ ខេត្តព្រៃវែង ។

មាត្រា ៦.-

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងព្រៃវែង ត្រូវអនុលោមទៅតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

មាត្រា ៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តព្រៃវែង អភិបាលស្រុកស្វាយអន្ទរ អភិបាលក្រុងព្រៃវែង អភិបាលស្រុកកំពង់លាវ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៥

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

www.pheakdeylaw.com




បញ្ជាក់
លេខ:......
បានឃើញ និង ឯកភាព
ក្រុងព្រៃវែង.ថ្ងៃទី......ខែ......ឆ្នាំ២០០៨
អភិបាលរងខេត្ត

អ៊ុង_សារី

បញ្ជាក់
លេខ:......
បានពិនិត្យត្រឹមត្រូវ
គោរពជូនឯកឧត្តមអភិបាលខេត្តពិនិត្យសំរេច
ធ្វើនៅថ្ងៃទី......ខែ......ឆ្នាំ២០០៨
ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម
សំណង់ និងសុរិយោដីខេត្តព្រៃវែង

ទិត្យករ.ទៃ_សុផល

បញ្ជាក់
លេខ:......
បានពិនិត្យ និង គោរពជូន
ឯកឧត្តមអភិបាលខេត្តពិនិត្យសំរេច
កំពង់លាវ.ថ្ងៃទី......ខែ......ឆ្នាំ២០០៨
អភិបាលស្រុក

កែវ_សេង

ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៨
អ្នករៀបចំផែនទី

ធឿន រ៉ាវុធណា

លេខ......
បានឃើញ និង ឯកភាព
ភ្នំពេញ.ថ្ងៃទី......ខែ......ឆ្នាំ២០០៩
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

www.pheakdeylaw.com